# សេចក្តីណែនាំ

# ស្តីពី

# ស្តីអំពីតួនាទី និងភារកិច្ច
# របស់មន្ត្រីរាជការប្រចាំការខុទ្ទកាល័យ

**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

គណៈរដ្ឋមន្ត្រី

ក្រសួងគ្រប់គ្រងបរិស្ថាន

លេខ: 1315 ប.ស្ថ.

រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ 7 ឆ្នាំ១៩៩5

# សេចក្តីណែនាំ

## ស្តីអំពីតួនាទីនិងភារកិច្ច
## របស់មន្ត្រីរាជការប្រចាំការឧទ្យានជាតិ

អនុវត្តព្រះរាជក្រឹត្យចុះថ្ងៃទី 1 ខែ វិច្ឆិកា ឆ្នាំ 1993 និងអនុវត្តគោលនយោបាយ របស់រាជរដ្ឋាភិបាលក្នុងការថែរក្សាការពារតំបន់ការពារធម្មជាតិ ក្រសួងគ្រប់គ្រងបរិស្ថាន បានដំណើរការរៀបចំដាក់ការងារ ឧទ្យានជាតិព្រះសីហនុ ឧទ្យានជាតិព្រះសុរាម្រិត-កុសមៈ (គិរីរម្យ) និងបន្តការរៀបចំរដ្ឋបាល តំបន់ការពារធម្មជាតិផ្សេងៗទៀត ។

ដើម្បីមានមូលដ្ឋាន ក្នុងការគ្រប់គ្រងថែរក្សាការពារ និងដំណើរការឧទ្យានជាតិបានល្អប្រសើរ ទោះអនាគត ក្រសួងគ្រប់គ្រងបរិស្ថាន សូមធ្វើការណែនាំពីតួនាទី និងភារកិច្ចរបស់មន្ត្រីរាជការ ដែលប្រចាំការនៅឧទ្យានជាតិ ដូចតទៅ :

1- សិក្សាស្វែងយល់អំពីស្ថានភាពភូមិសាស្ត្រ និងកំណត់ទីតាំងព្រំប្រទល់ឧទ្យានជាតិឲ្យបានច្បាស់លាស់ ។

2- សិក្សាស្រាវជ្រាវប្រមូលទិន្នន័យ (ប្រភេទសត្វ រុក្ខជាតិ ក្នុងតំបន់ឧទ្យានជាតិ និងធ្វើបញ្ជីសារពើភ័ណ្ឌ )។

3- សិក្សាស្រាវជ្រាវអំពីសក្តានុពលភាព ធ្វើការបែងចែក និងកំណត់តំបន់ឲ្យបានច្បាស់លាស់ ដើម្បីអភិរក្ស និងអភិវឌ្ឍន៍ ។

4- ធ្វើការសិក្សាស្រាវជ្រាវឡើងវិញ នូវរាល់បញ្ហាប្រពន្ធ័ផ្លូវនៅតំបន់ឧទ្យានជាតិ ។

5- សិក្សាស្វែងយល់ឲ្យបានស៊ីជំរៅលើផ្នែកធម្មជាតិ និងមានទេពកោសល្យ ក្នុងការបកស្រាយធម្មជាតិ ។

6- ត្រូវសហការណ៍ និងសំរបសំរួលការងារយ៉ាងជិតស្និត ជាមួយកងកំលាំងប្រដាប់អាវុធ នគរបាលជាតិ រដ្ឋអំណាចមូលដ្ឋាន ស្ថាប័នពាក់ព័ន្ធ និងប្រជាជនមូលដ្ឋានក្នុងការការពារធម្មជាតិ ។

7- សិក្សាស្រាវជ្រាវអំពីសេដ្ឋកិច្ចសង្គមរបស់ប្រជាជននៅក្នុង ឬនៅជុំវិញតំបន់ ដែលមានឥទ្ធិពល មកលើឧទ្យានជាតិ ។



លេខ ៤៨ វិថីព្រះសីហនុ ទន្លេបាសាក់ ខណ្ឌចំការមន ភ្នំពេញ ទូរស័ព្ទ 27894 / 015 914 055 ទូរសារ 855 23 27844

8- ត្រូវសហការណ៍ជាមួយស្ថាប័នពាក់ព័ន្ធ ក្នុងការចុះយាមល្បាតត្រួតពិនិត្យភាពអនាធិបតេយ្យ ដូចជាការកាប់បំផ្លាញព្រៃឈើ ការបរបាញ់សត្វព្រៃគ្រប់ប្រភេទ ការធ្វើអាជីវកម្មអនុផលព្រៃឈើ ការកាប់ឆ្ការព្រៃ ដើម្បីយកដីមកធ្វើជាកម្មសិទ្ធ ឬប្រកបរបរផ្សេងៗទៀត ។ល។ និង ។ល។

9- ក្នុងករណីដែលជួបប្រទះនូវភាពអនាធិបតេយ្យដោយប្រការណាមួយ ដូចមានចែងក្នុងចំណុច 8 ក្រុមបេសកកម្ម ត្រូវអនុវត្តៈ

- ធ្វើការពន្យល់ ណែនាំ និងអប់រំដល់ជនល្មើស

- សហការណ៍ជាមួយស្ថាប័នពាក់ព័ន្ធ ដើម្បីឃាត់ទុកវត្ថុតាងទាំងឡាយ និងធ្វើបែបបទបញ្ជូនសំណុំលិខិតមកថ្នាក់ដឹកនាំក្រសួង ដើម្បីមានវិធានការណ៍ដោះស្រាយ ។

10- ត្រូវមានការយល់ដឹង ពីបទបញ្ជាឧទ្យានជាតិ និងធ្វើការផ្សព្វផ្សាយឱ្យបានទូលំទូលាយ ដល់ប្រជាជនដែលរស់នៅក្នុង និងជុំវិញតំបន់ឧទ្យានជាតិ ព្រមទាំងភ្ញៀវទេសចរណ៍ ដែលមកទស្សនាឧទ្យានជាតិ ។

11- ត្រូវធានាសុវត្ថិភាព និងបង្កភាពរីករាយដល់ភ្ញៀវទេសចរណ៍ ដែលចូលទស្សនា (ត្រូវដាក់ផ្លាកសញ្ញា បង្ហាញពីកន្លែង ដែលមានគ្រោះថ្នាក់ និងកន្លែងដែលត្រូវចូលទស្សនា ) ។

12- ត្រូវមានទំនាក់ទំនងល្អជាមួយភ្ញៀវទេសចរណ៍ និងទំនាក់ទំនងជាមួយបណ្តា អ្នកសារពត៌មាន ក្នុងនិងក្រៅប្រទេស វិទ្យុ ទូរទស្សន៍ កាសែត ។ល។ ដើម្បីឱ្យផ្សព្វផ្សាយ អំពីសក្តានុពលភាព នៃឧទ្យានជាតិ ។

13- ត្រួតពិនិត្យ និងមានវិធានការណ៍ទប់ស្កាត់នូវភ្លើងឆេះព្រៃ ។

14- ជារៀងរាល់ដំណាច់ខែ ត្រូវធ្វើរបាយណ៍ពីសកម្មភាពការងារដែលអនុវត្តបាន និងពត៌មានផ្សេងៗដែលទទួលបាន ពីការចុះពិនិត្យអង្កេតសភាពការណ៍ ដែលកើតមានឡើងក្នុងឧទ្យានជាតិ ព្រមទាំងធ្វើទិសដៅផែនការ បញ្ជូនមកក្រសួងគ្រប់គ្រងបរិស្ថាន "នាយកដ្ឋានការពារអភិរក្សធម្មជាតិ" ជារៀងរាល់ថ្ងៃទី 25 នៃខែនីមួយៗ ។

នាយកដ្ឋានការពារអភិរក្សធម្មជាតិ មន្ទីរគ្រប់គ្រងបរិស្ថានខេត្ត-ក្រុង ដែលមានតំបន់ការពារធម្មជាតិ មានភារកិច្ចអនុវត្តសេចក្តីណែនាំនេះ ឱ្យមានប្រសិទ្ធិភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

<u>ចំលងជូន</u>

- ទីស្តីការគណៈរដ្ឋមន្ត្រី
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ក្រសួងកសិកម្ម រុក្ខា-ប្រមាញ់ និងនេសាទ
- ក្រសួងការពារជាតិ
- ក្រសួងមហាផ្ទៃ
- អភិបាលខេត្ត-ក្រុងពាក់ព័ន្ធ
- ចំណុចចុងក្រោយ
- ឯកសារ

បណ្ឌិត ម៉ុក-ម៉ារ៉េត

File:Dept.\sei..\Kalyan